Australian Government
Asbestos Safety and Eradication Agency

ខែមេសា ឆ្នាំ2019

# ចំណុចសំខាន់ៗរបស់គ្រីសូថាយ (Chrysotile)

## តើអ្វីទៅជាអះបេះស្តុះគ្រីសូថាយ ?

- គ្រីសូថាយគឺជាអះបេះស្តុះ
- អះបេះស្តុះគឺជាពាក្យគេប្រើសម្រាប់រៀបរាប់ក្រុមនៃធាតុរ៉ែប្រាំមួយមុខជាសរសៃៗកើតឡើងដោយធម្មជាតិ។ ជាតិសរសៃទាំងនេះមានជាពីរក្រុម – អះបេះស្តុះប្រភេទ surpentine និងអះបេះស្តុះប្រភេទ amphibole ។
- គ្រីសូថាយគឺជាអះបេះស្តុះមួយប្រភេទគត់ដែលមានរូបរាងដូចពស់ ។
- គ្រីសូថាយគឺជាប្រភេទអះបេះស្តុះដែលគេឧស្សាហ៍ប្រទះឃើញជាងគេ។
- គ្រីសូថាយគឺជាអះបេះស្តុះដែលគេប្រើធ្វើអាជីវកម្មជាចំបង។

## តើគ្រីសូថាយអាចបង្កឲ្យមានជម្ងឺមហារីកសួតហៅថា mesothelioma ឬទេ ?

- **អាច**។ វាច្បាស់ហើយថា គ្រីសូថាយ អាចបង្កឲ្យមានជម្ងឺ mesothelioma (មហារីកសួតឬស្រទាប់ ប្រហោងនានាក្នុងពោះ)
- ឯកសារវិទ្យាសាស្ត្របឋមនានាដែលនិយាយអំពីរឿងនេះត្រូវបានគេធ្វើវិភាគជាប្រព័ន្ធនៅក្នុងរបាយការណ៍ច្រើនបន្តរបស់ស្ថាប័នវិទ្យាសាស្ត្រអន្តរជាតិ *
- របាយការណ៍ទាំងអស់បានកត់ត្រានិងវាយតម្លៃភស្តុតាងយ៉ាងច្រើនទាក់ទងនិងមនុស្ស (និងសត្វ) ហើយបានបញ្ជាក់ថា អះបេះស្តុះគ្រប់ប្រភេទ— រួមទាំងគ្រីសូថាយផង — គឺជាភ្នាក់ងារតែមួយគត់ដែលគេដឹងថាបង្កឲ្យមានជម្ងឺ mesothelioma ។

* របាយការណ៍ទាំងឡាយរួមមាន ៖ កម្មវិធីអន្តរជាតិស្តីអំពីសុវត្ថិភាពនៃជាតិគីមី (IPCS) របាយការណ៍ស្តីអំពីលក្ខណ:វិនិច្ឆ័យនៃសុខភាពបរិស្ថានរបស់អះបេះស្តុះគ្រីសូថាយ(IPCS–UNEP/ILO/WHO, 1998); របាយការណ៍របស់អង្គការសុខភាពពិភពលោកស្តីអំពីអះបេះស្តុះប្រភេទគ្រីសូថាយ (WHO, 2014); របាយការណ៍សិក្សាឯកទេសខាងអះបេះស្តុះរបស់ភ្នាក់ងារអន្តរជាតិខាងការស្រាវជ្រាវវិស័យមហារីករបស់អង្គការសុខភាពពិភពលោក(IARC, 2012); របាយការណ៍ស្តីអំពីវត្ថុធាតុទាំងឡាយដែលងាយបង្កឲ្យកើតមហារីករៀបរៀងឡើងដោយក្រសួងសុខាភិបាលសហរដ្ឋអាមេរិក និងភ្នាក់ងារសេវាកម្មមនុស្សជាតិសម្រាប់រក្សាបញ្ជីសារជាតិពុលនិងជម្ងឺ(ATSDR) ទ្រង់ទ្រាយនៃជាតិពុលរបស់អះបេះស្តុះ (ATSDR, 2001) កម្មវិធីនៃការសិក្សាជាតិពុលថ្នាក់ជាតិ(NTP, 2016); និងសេចក្តីសង្ខេបនៃការវាយតម្លៃផ្នែកគីមីនៃអះបេះស្តុះរបស់ស្ថាប័នការពារបរិស្ថានរបស់សហរដ្ឋអាមេរិក(EPA) ប្រព័ន្ធព័ត៌មានស្តីអំពីហានិភ័យ(IRIS) (US EPA, 1988)។ របាយការណ៍អស់ទាំងនេះបង្ហាញឲ្យឃើញការវាយតម្លៃលើគ្រោះថ្នាក់(i.e. IARC, 2012) ក៏ដូចជាការវាយតម្លៃនៃហានិភ័យជាទូទៅផងដែរ(i.e. ATSDR, 2001; IPCS–UNEP/ILO/WHO 1998; US EPA, 1988)។ នៅក្រោមច្បាប់នៃការគ្រប់គ្រងសារធាតុពុលដែលបានធ្វើវិសោធនកម្ម(TSCA) EPA របស់សហរដ្ឋអាមេរិកក៏បានរាប់បញ្ចូលអះបេះស្តុះទៅក្នុងសារធាតុគីមីចំនួន១០ដំបូងគេដែលត្រូវវាយតម្លៃអំពីហានិភ័យឲ្យបានត្រឹមត្រូវទាន់សម័យ ហើយឯកសារមួយដែលរៀបរាប់ជាក់ច្បាស់អំពីបញ្ហាក៏ត្រូវបានកសាងឡើងថ្មីៗនេះ(US EPA, 2018)។

## តើប្រភេទមហារីកអ្វីទៀតដែលគ្រីសូថាយ អាចបង្កឲ្យមាន ?

- គ្រីសូថាយក៏អាចបង្កឲ្យកើតមហារីកប្រភេទដទៃដែរ រួមទាំងមហារីកដែលគេឧស្សាហ៍ប្រទះឃើញបំផុតដែលទាក់ទងនឹងការប៉ះប្រទះនិងអះបេះស្តុះ គឺមហារីកសួត ក៏ដូចជាមហារីកឃោសិត្រ(Larynx) និងដៃស្បូន។
- គ្រីសូថាយក៏មានការពាក់ព័ន្ធនិងមហារីកចុងខាងលើនៃបំពង់អាហារ(Pharynx) ក្រពះ និងពោះវៀនធំផងដែរ(IARC, 2012)។

## តើសព្វថ្ងៃវិទ្យាសាស្ត្រស្ថិតនៅដំណាក់ណាស្តីអំពី គ្រីសូថាយ ?

ASBESTOS SAFETY

- វិទ្យាសាស្ត្រស្តីអំពីហានិភ័យក្នុងការកើតជម្ងឺរបស់មនុស្ស (ដូចជាមហារីកគ្រប់ប្រភេទនិងជម្ងឺសួតរ៉ាំរៃ) បន្ទាប់ពីបានប៉ះប្រទះអះបេះស្តុះក្នុងទ្រង់ទ្រាយណាមួយក៏ដោយ— រួមទាំងគ្រីសូថាយផង—គឺច្បាស់ក្រឡែត។

- សូម្បីតែការវាយតម្លៃដោយសាមញ្ញមួយលើសេចក្តីអធិប្បាយវិទ្យាសាស្ត្របឋមថ្មីៗបំផុត បានបញ្ជាក់នូវភស្តុតាងយ៉ាងសន្ធឹកសន្ធាប់ថាអះបេះស្តុះ— រួមទាំងគ្រីសូថាយផង—ជាបញ្ហាសុខភាពធំ ដែលបង្កើតឲ្យមានជម្ងឺដ៏គ្រោះថ្នាក់ទូទាំងពិភពលោក ដែលចេញមកពីការប៉ះប្រទះពីមុនមកក៏ដូចជាបច្ចុប្បន្ននេះនៅកន្លែងធ្វើការ អាគារសាធារណៈដូចជាសាលារៀន មន្ទីរពេទ្យហើយនិងទីកន្លែងដែលមិនមែនជាកន្លែងធ្វើការដូចជាផ្ទះនៅជាដើម។

- គេគ្មានត្រូវការស្រាវជ្រាវថ្មីណាទៀតទេដើម្បីបញ្ជាក់ទំនាក់ទំនងរវាងអះបេះស្តុះនិងជម្ងឺដែលកើតឡើងដោយទាក់ទងនិងអះបេះស្តុះ។ ភាពខុសគ្នារវាងកម្លាំងនៃការបង្កឲ្យមានជម្ងឺរបស់ប្រភេទខុសៗគ្នានៃអះបេះស្តុះនោះ មិនមានន័យសំខាន់ទេ–ទាំងអស់នោះសុទ្ធតែបង្កឲ្យមានជម្ងឺ។ ថែមពីលើនេះទៀត ភាពខុសគ្នារវាងការបង្កដោយអះបេះស្តុះខុសៗគ្នាឲ្យមានជម្ងឺមិនជ្រុះចេញពីសួត(bio persistence ) ក៏មិនមានន័យសំខាន់ដែរ។ គេបានបញ្ជាក់ច្បាស់ហើយថាការផ្តុំគឡើងនៃសរសៃអះបេះស្តុះ ជាពិសេសគ្រីសូថាយ នៅក្នុងជាលិកាទ្រាប់សួត គឺបង្កឲ្យកើតជម្ងឺ mesothelioma (ឧ. Suzuki និង Yuen, 2006; Kohyama និង Suzuki, ឆ្នាំ1991។

- ព័ត៌មានថ្មីៗស្តីអំពីការសិក្សាស្រាវជ្រាវអំពីជម្ងឺដែលអាចប៉ះពាល់ប្រជាពលរដ្ឋទាំងហ្វូងនោះ នៅតែមានបន្តប្រមូលជាច្រើនឆ្នាំទៅមុខទៀត ហើយដែលប្រាកដជាមានបន្ថែមទៅលើការស្រាវជ្រាវដ៏ធំបច្ចុប្បន្ននេះ។

- វិទ្យាសាស្ត្រថ្មីគួរតែផ្តោតទៅលើអនាគត។ ឧទាហរណ៍ ដូចជាការយល់ដឹងអំពីកំរិតនៃការប៉ះប្រទះវត្ថុដែលមានជាតិអះបេះស្តុះដែលវត្ថុនោះមាននៅនិងកន្លែងស្រាប់ ហើយនិងការយកវាចេញ; ការយល់ដឹងអំពីយន្តការខាងក្នុងរបស់ជម្ងឺទាក់ទងនិងអះបេះស្តុះដើម្បីបង្កើនជម្រើសនៃការព្យាបាលដែលកាត់បន្ថយភាពគ្រោះថ្នាក់ដល់សុខភាពបង្កដោយការប៉ះប្រទះអះបេះស្តុះ ហើយនិងធ្វើឲ្យបន្ទុកនៃជម្ងឺក្នុងពិភពលោកទាក់ទងនិងអះបេះស្តុះមានការថយចុះ; ការបង្កើតរបៀបថ្មីៗក្នុងការចោលអះបេះស្តុះដោយប្រើវិធីហួសពីវិធីបច្ចុប្បន្នដែលចោលនៅគំនរចាក់សម្រាម(ឧ. ការបំឡែងអះបេះស្តុះដោយប្រើកំដៅឬវិធីគីមី) ដើម្បីធានាឲ្យការដោះស្រាយបញ្ហានេះមានចេរភាព។

## តើការប្រើដោយមានការទទួលខុសត្រូវនិងដោយសុវត្ថិភាព អាចបានឬទេ ?

- **មិនបានទេ** ។ គ្រីសូថាយបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស ដោយសារវាអាចបង្កឲ្យកើតមហារីកនិងជម្ងឺដទៃៗទៀត។

- ពុំមានភស្តុតាងដែលថាមានកំរិតមួយដែលផ្តល់សុវត្ថិភាពនោះទេដើម្បីការពារមិនឲ្យមានផលអវិជ្ជមានពីការប្រើអះបេះស្តុះ។ ដោយសារយើងពុំដឹងថាកំរិតនៃការប៉ះប្រទះអះបេះស្តុះនោះប៉ុន្មានដែលធ្វើឲ្យយើងមិនកើតជម្ងឺទាក់ទងនិងអះបេះស្តុះនោះ ហានិភ័យចំពោះសុខភាពមនុស្សដែលអាចកើតឡើងនៅពេលអះបេះស្តុះត្រូវមានគេប៉ះពាល់ឬពេលវាចេះតែពុកទៅនោះ គឺមិនអាចទទួលយកបានឡើយ។

- ដោយគ្មានកំរិតនៃការប៉ះប្រទះណាប្រកបដោយសុវត្ថិភាព ការប្រើនៅក្នុងបរិស្ថានប្រកបដោយការគ្រប់គ្រង មិនអាចធ្វើបានទេ ព្រោះគេពុំអាចបំបាត់ហានិភ័យនៃការប៉ះប្រទះបានឡើយ។

- កន្លែងការងារទាំងឡាយអាចដាក់វិធានការណ៍ដែលអាចកាត់បន្ថយហានិភ័យនៃការប៉ះប្រទះឲ្យនៅជាអប្បបរិមាដោយប្រើយន្តការគ្រប់គ្រងប្រកបដោយរចនាសម្ព័ន្ធ ប៉ុន្តែការធ្វើដូច្នេះមិនអាចការពារមិនឲ្យមានការប៉ះប្រទះទាំងស្រុងបានឡើយលុះណាតែអះបេះស្តុះ(ឬភាពគ្រោះថ្នាក់)ត្រូវបានបំបាត់ឲ្យអស់ទាំងស្រុង។

- វត្តមានឬក៏ការប្រើថ្មីនៃសម្ភារៈដែលមានអះបេះស្តុះនៅតំបន់ដែលមានសំណង់ (ផ្ទះឬកន្លែងធ្វើការ) បង្កឲ្យសង្គមយ៉ាងធំមានហានិភ័យ ព្រោះសម្ភារៈនៃការសាងសង់យូរទៅត្រូវមានការជួសជុល ដែលជៀសមិនផុតពីការធ្វើអ្វីនានាទៅលើផ្ទៃរបស់វា ឬការយកចេញទាំងស្រុង ដែលពេលនោះធ្វើឲ្យមានការជ្រុះហើរសរសៃអះបេះស្តុះ។

- គ្រោះធម្មជាតិ (ការរំជួយផែនដី ខ្យល់ព្យុះ រលកយក្ស និងទឹកជំនន់) ក៏ពុំមានបញ្ចូលយុទ្ធវិធីគ្រប់គ្រងដើម្បីថែទាំវត្ថុដែលមានអះបេះស្តុះនៅទីដែលមានសំណង់ឡើយ។

## តើផលិទ្ធផលជំនួសទាំងឡាយមានសុវត្ថិភាព ថោក ហើយនិងអាចដាក់ប្រើឲ្យត្រូវនិងស្ថានភាពមូលដ្ឋានដែរឬទេ ?

- **មាន**។ ដោយឃើញការធ្វើឲ្យខូចដល់សុខភាពបង្កដោយការប្រើអះបេះស្តុះ—រួមទាំងគ្រីសូថាយ—គេក៏បានធ្វើការស្រាវជ្រាវយ៉ាងច្រើនក្នុងទស្សវត្តជាច្រើនកន្លងមកលើសម្ភារៈជំនួសអះបេះស្តុំ។ #

- សម្ភារៈដែលប្រកបដោយសុវត្ថិភាពនិងមានប្រសិទ្ធិភាព គឺគេអាចរកបានសម្រាប់ជំនួសសម្ភារៈពីមុនទាំងអស់ដែលខាងក្នុងមានអះបេះស្តុះ។ ទោះបីជាតិគីមីមួយមិនអាចជំនួសអះបេះស្តុះបាន មានសម្ភារៈជំនួសដែលមានលក្ខណៈបច្ចេកទេសនិងតម្លៃសមស្រប (រួមទាំងមានសរសៃ [ឧ. cellulose] និងមិនមានសរសៃ [ឧ. ផ្លាស្ទិក និងលោហធាតុ] អាស្រ័យទៅលើការប្រើជាចុងក្រោយ) គេកំពុងប្រើតាមរយៈការជួញដូរទូទាំងពិភពលោក និងជាពិសេសក្នុងប្រទេសទាំងពួងដែលបានហាមការប្រើអះបេះស្តុះគ្រីសូថាយក្នុងរយៈពេល៥០ឆ្នាំកន្លងមក។ គ្រប់ជាតិគីមីទាំងអស់មានលក្ខណៈសម្បត្តិខុសៗគ្នាដែលអាស្រ័យលើការប្រើប្រាស់វាអាចបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស។ គេអាចឲ្យនិយមន័យលើការប្រើជាតិគីមីប្រកបដោយសុវត្ថិភាពដោយវាយតម្លៃទាំងភាពបង្កឲ្យមានគ្រោះថ្នាក់ផង និងភាពងាយឲ្យគេប៉ះប្រទះផង ដើម្បីរកកំរិតហានិភ័យជាទូទៅ។ គេមិនអាចមើលតែភាពបង្កឲ្យមានគ្រោះថ្នាក់ ឬតែភាពឲ្យគេងាយប៉ះប្រទះដាច់ពីគ្នានោះទេ ក្នុងការរកហានិភ័យជាទូទៅ។

- នៅក្នុងប្រទេសអូស្ត្រាលី សម្ភារៈជំនួសគ្រីសូថាយមានតាំងពីមុនឆ្នាំ១៩៩៩មកម្ល៉េះ។ ការប្រើនេះមានរួមទាំងនៅឧស្សាហកម្មធំៗ គឺមានទាំងខាងសំណង់ យានយន្ត និងអាយៈស្វ័យយាន។ លក្ខណៈសម្បត្តិគីមី កត្តាវិជ្ជមាននិងអវិជ្ជមាន ហើយនិងផលប៉ះពាល់ដល់សុខភាពទាំងឡាយរបស់សម្ភារៈជំនួស ត្រូវបានគេសង្ខេបតាំងពីមុនមកហើយ (NICNAS, 1999)។

- អង្គការសុខភាពពិភពលោក (The WHO ) បានប្តេជ្ញាចិត្តផ្តល់ព័ត៌មាននិងការលើកទឹកចិត្តជាសេដ្ឋកិច្ចចំពោះការផ្លាស់អះបេះស្តុះចេញហើយយកសម្ភារៈដែលមានសុវត្ថិភាពជាងជំនួសវិញ(WHO, 2014)។

# វិទ្យាស្ថានសម្រាប់បរិស្ថាននិងសុខភាព(IEH) ឆ្នាំ 2000 វិទ្យាស្ថានជាតិនៃវិទ្យាសាស្ត្រឧស្សាហកម្ម និងបច្ចេកវិទ្យាជឿនលឿន (AIST) ឆ្នាំ 2007 របាយការណ៍ឆ្នាំ១៩៨២ របស់ US EPA ស្តីអំពីការវិភាគលើប្រសិទ្ធិភាពរបស់សម្ភារៈជំនួសអះបេះស្តុះ របាយការណ៍ស្តីអំពីអះបេះស្តុះគ្រីសូថាយនិងសម្ភារៈដែលអាចប្រើជំនួសបាន ឆ្នាំ១៩៩៨ និងកែលំអឆ្នាំ២០០២ របស់គណៈកម្មាធិការវិទ្យាសាស្ត្ររបស់សហភាពអឺរ៉ុបក្នុងវិស័យជាតិពុល ជាតិពុលក្នុងបរិស្ថាន និងបរិស្ថាន(CSTEE)

## តើអង្គការសុខភាពពិភពលោកមានជំហរដូចម្តេច ?

- អង្គការសុខភាពពិភពលោកគិតថា អះបេះស្តុះស្ថិតក្នុងចំណោមវត្ថុដែលអាចបង្កឲ្យមានមហារីកដោយសារអាជីពសំខាន់ជាងគេ(WHO, 2014)។ អះបេះស្តុះ —រួមទាំងគ្រីសូថាយផង—បង្កឲ្យមានជម្ងឺ mesothelioma ជម្ងឺមហារីកសួត មហារីកឃោសិត្រ និងមហារីកដៃស្បូន; ជម្ងឺ asbestosis (ភាពក្រិននៃសួត) ; និងជម្ងឺក្នុងដងខ្លួនដូចជា plaques ការធ្វើឲ្យទឹកខាប់ ឬលេចទឹកចេញ។ អង្គការសុខភាពពិភពលោកបានធ្វើអនុសាសន៍សុំឲ្យមានការផ្តោតអារម្មណ៍លើការកំចាត់ឲ្យអស់ជម្ងឺដែលទាក់ទងនិងអះបេះស្តុះ ចាប់ផ្តើមឡើងនាឆ្នាំ២០០៣ ក្នុងសម័យទី១៣នៃអង្គប្រជុំរួមរវាងអង្គការពលកម្មអន្តរជាតិ(ILO)និងកម្មាធិការស្តីអំពីសុខភាពនៃអង្គការសុខភាពពិភពលោក។

- ការសម្រេចរបស់អង្គសន្និបាតសុខភាពពិភពលោកដែលស្នើឲ្យមានយុទ្ធនាការផ្សព្វផ្សាយកំចាត់ឲ្យអស់ជម្ងឺទាក់ទងនិងអះបេះស្តុះ ត្រូវបានដាក់ក្នុងរបៀបវារៈនាឆ្នាំ២០០៧។ អង្គការសុខភាពពិភពលោកក៏បានចែងយុទ្ធសាស្ត្រដើម្បីការកំចាត់ឲ្យអស់ជម្ងឺទាក់ទងនិងអះបេះស្តុះដែលរួមមានការទទួលស្គាល់ថា ការឈប់ប្រើអះបេះស្តុះគ្រប់ប្រភេទជាវិធីដែលមានប្រសិទ្ធិភាពបំផុត(WHO, 2014; IPCS–UNEP/ILO/WHO, ឆ្នាំ1998)។

## តើ IARC មានជំហរយ៉ាងណា ?

- អង្គការអន្តរជាតិទទួលបន្ទុកការស្រាវជ្រាវអំពីមហារីក (IARC) ចាត់ទុកថាគ្រប់ទ្រង់ទ្រាយទាំងអស់នៃអះបេះស្តុះ—រួមទាំងគ្រីសូថាយផង— ជាវត្ថុដែលងាយបង្កមហារីកដល់មនុស្សជាតិ (ក្រុមទី១)។ ជាមួយនិងមនុស្ស មានភស្តុតាងដែលបង្ហាញច្បាស់ថា អះបេះស្តុះ— រួមទាំងគ្រីសូថាយផង—បង្កឲ្យមានជម្ងឺ mesothelioma មហារីកសួត

មហាវិកឃោសិត្រ និងមហាវិកដៃស្បូន។ មានទំនាក់ទំនងវិជ្ជមានផងដែររវាងការប៉ះប្រទះអះបេះស្តុះ— រួមទាំងគ្រីសូថាយផង— និងមហារីកចុងខាងលើនៃបំពង់អាហារ មហារីកក្រពះ និងពោះមហារីកពោះវៀនធំ(IARC, 2012)។

## តើ ILO 162 អនុញ្ញាតិឲ្យមានការបន្តប្រើអះបេះស្តុះគ្រីសូថាយឬ ?

- **មិនមែនទេ**។ ILO 162 (ដែលដោះស្រាយរឿងការប៉ះប្រទះរបស់កម្មករធ្វើការជាមួយនិងអះបេះស្តុះនៅកន្លែងធ្វើការ) មិនគួរត្រូវបានគេប្រើដើម្បីជាសំអាងសម្រាប់ការបន្តប្រើអះបេះស្តុះរួមទាំងអះបេះស្តុះគ្រីសូថាយផងនោះឡើយ។

- ការសម្រេចទាក់ទងនិងអះបេះស្តុះត្រូវបានអនុម័តយកដោយអង្គប្រជុំរបស់ពលកម្មអន្តរជាតិនៅក្នុងអង្គសន្និបាតទី៩៥ នាឆ្នាំ២០០៦។ អង្គសន្និបាតនោះបានអំពាវនាវឲ្យមានការកំចាត់ឲ្យអស់ការប្រើអះបេះស្តុះក្នុងអនាគត និងការសំគាល់ឲ្យដឹងនិងការគ្រប់គ្រងឲ្យបានត្រឹមត្រូវចំពោះអះបេះស្តុះដែលមាននាពេលបច្ចុប្បន្ននេះ ថាជាវិធីដែលមានប្រសិទ្ធិភាពបំផុតដើម្បីការពារកម្មករធ្វើការពីការប៉ះប្រទះអះបេះស្តុះ ហើយនិងការពារកុំឲ្យមានជម្ងឺនិងការស្លាប់ដោយសារទាក់ទងនិងអះបេះស្តុះក្នុងអនាគត។

- សេចក្តីសម្រេចក៏បានសង្កត់ថា កិច្ចប្រជុំរបស់ ILO ស្តីអំពីសុវត្ថិភាពក្នុងការប្រើអះបេះស្តុះ មិនគួរត្រូវគេប្រើជាមូលហេតុថាត្រឹមត្រូវក្នុងការបន្តប្រើអះបេះស្តុះគ្រីសូថាយឡើយ។

## ហេតុអ្វីបានជាប្រទេសអូស្រ្តាលីហាមមិនឲ្យប្រើគ្រីសូថាយ ?

- គ្រីសូថាយត្រូវបានហាមមិនឲ្យប្រើក្នុងប្រទេសអូស្រ្តាលីជាង១៥ឆ្នាំហើយ គឺចាប់តាំងពីថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៣ មក។

- កាលពី២០ឆ្នាំមុន ស្ថាប័ន NICNAS (កម្មវិធីថ្នាក់ជាតិសម្រាប់ផ្តល់ដំណឹងនិងវាយតម្លៃជាតិគីមីសម្រាប់ឧស្សាហកម្ម) បានវាយតម្លៃថា គ្រីសូថាយជាគីមីបច្ចុប្បន្នដែលមានអាទិភាព(PEC) ដោយគិតអំពីហានិភ័យក្នុងការងារ សុខភាពមនុស្ស និងបរិស្ថាន(NICNAS, ឆ្នាំ1999)។

- ផ្អែកទៅលើវិទ្យាសាស្រ្តដែលមាននាពេលនោះ របាយការណ៍នេះបានស្នើថា ដើម្បីការពារសុខភាពមនុស្ស ការប៉ះប្រទះទាំងអស់គួរតែជៀសវាង។ សេចក្តីសន្និដ្ឋានទាំងឡាយដដែលនោះនៅតែត្រូវនៅថ្ងៃនេះ និងមានភស្តុតាងបន្ថែមទៀតដែលគេប្រមូលបានក្រោយពីពេលនោះផង។

- ការវាយតម្លៃរបស់ PEC អំពីគ្រីសូថាយ ក៏មាននិយាយអំពីបញ្ហាទាំងឡាយជុំវិញផលប៉ះពាល់សុខភាពពីសំណាក់ផលិទ្ធផលជំនួសទាំងពួង ហើយក៏បានលាតត្រដាងឲ្យគេដឹងអំពីការយល់ខុសដែលថាសម្ភារៈទាំងនោះបង្កឲ្យមានហានិភ័យដល់សុខភាពនិងសុវត្ថិភាពកាន់តែខ្ពស់ជាងទៅទៀត។

- ការវាយតម្លៃរបស់ PEC នៅតែអាចធ្វើបាន ប៉ុន្តែការហាមមិនឲ្យប្រើគ្រីសូថាយមានន័យថា គ្មានមូលដ្ឋានដែលត្រូវកែប្រែវាទេ។ ទោះជាយ៉ាងណា ដោយសារប្រវត្តនៃការប្រើប្រាស់អះបេះស្តុះក្នុងប្រទេសអូស្រ្តាលី ហើយនិងការបន្តប្រើផលិទ្ធផលដែលខាងក្នុងមានជាតិអះបេះស្តុះនៅប្រទេសកំពុងអភិវឌ្ឍន៍ ការយល់ដឹងអំពីហានិភ័យពីការប៉ះប្រទះផលិទ្ធផលដែលកំពុងដាក់ប្រើហើយ គឺជាប្រធានបទដ៏សំខាន់សម្រាប់ការស្រាវជ្រាវ។

## តើគេត្រូវការការហាមមិនឲ្យប្រើទូទាំងពិភពលោកឬទេ ?

- **ត្រូវ**។ ការហាមទូទាំងពិភពលោកត្រូវធ្វើឥឡូវហ្នឹង។

- បន្ទុកពីជម្ងឺទាក់ទងនិងអះបេះស្តុះទូទាំងពិភពលោកគឺខ្ពស់ ហើយមានតែបន្តកើនឡើងបើការប្រើនៅតែមានបន្ត។ មានមេរៀនយ៉ាងច្បាស់ពីបទពិសោធន៍ពីប្រទេសនានាដូចជាប្រទេសស្រ្តាលីជាដើម ដែលពីមុនអូស្រ្តាលីជាប្រទេសមួយក្នុងចំណោមប្រទេសដែលប្រើអះបេះស្តុះច្រើនជាងគេបង្អស់ក្នុងពិភពលោក គិតជាភាគរយក្នុងប្រជាពលរដ្ឋម្នាក់ៗ(ទ្រង់ទ្រាយអះបេះស្តុះថ្នាក់ជាតិ(NAP)សម្រាប់ប្រទេសអូស្រ្តាលីឆ្នាំ២០១៧)។ ប្រទេសអូស្រ្តាលីចាប់ផ្តើមដាក់កំហិតក្នុងការប្រើប្រាស់អះបេះស្តុះនៅឆ្នាំ១៩៦០ ហើយអនុវត្តការហាមមិនឲ្យប្រើអះបេះស្តុះទាំងស្រុងនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣។ ទោះបីដូច្នេះក៏ដោយ ក៏ករណីជម្ងឺ mesothelioma បានកើនឡើងចាប់ ពីដើមទស្សវត្ត ១៩៨០មក ហើយការប៉ាន់ស្មានគឺនឹងមានជម្ងឺ mesothelioma ប្រមាណ ១៩០០០ ករណីពីឆ្នាំ២០១៥ ដល់ចុងសតវត្សនេះ (ASEA reports, 2016)។

- ការបារម្ភធំគឺថា ទោះបីការប្រើមានការគ្រប់គ្រងដោយមាននីយ័តកម្មត្រឹមត្រូវ សម្ភារៈសំណង់ដែលមានជាតិគ្រីសូថាយ (ដូចជាក្បឿង បំពង់ទឹក។ល។)នឹងបាក់បែកធ្វើឲ្យសរសៃអះបេះស្តុះធ្លាក់ហើរនៅក្នុងបរិស្ថាននៅពេលគេជួសជុល រុះ និងបោះចោលកាកសំណល់សំណង់ ហើយនិងបន្ទាប់ពីមានគ្រោះធម្មជាតិទាំងឡាយ។ ការប៉ះប្រទះទាំងនេះ គេនឹកថានឹងកើតឡើងក្រោយពេលតម្លើងដំបូង(ដែលស្ថិតក្នុងការគ្រប់គ្រង)។ ហានិភ័យនេះអាចបញ្ចៀសបានទាំងស្រុងដោយឈប់ប្រើសម្ភារៈទាំងនោះ។

- ព័ត៌មានអំពីសម្ភារៈនិងផលិទ្ធផលជំនួសដែលអាចប្រើបានដោយសុវត្ថិភាព គេអាចរកបានពីស្ថាប័នថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។
ការប្រើសម្ភារៈនិងផលិទ្ធផលជំនួសនឹងមិនធ្វើឲ្យប៉ះពាល់ដល់គុណភាពនៃការរស់នៅឡើយនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ព្រោះមានសម្ភារៈជំនួសដែលមានសុវត្ថិភាពនិងប្រសិទ្ធិភាពសម្រាប់មនុស្សគ្រប់រូប។
ការហាមប្រើអះបេះស្តុះទាំងស្រុងគឺជាវិធីដែលមានប្រសិទ្ធិភាពបំផុតក្នុងការកំចាត់ជម្ងឺដែលទាក់ទងនិងអះបេះស្តុះ។

Australian Government
Asbestos Safety and Eradication Agency

ខែមេសា ឆ្នាំ2019

## ឯកសារយោង


ភ្នាក់ងារទទួលបន្ទុកកត់ត្រានិងរក្សាទិន្នន័យអំពីជាតិពុលនិងជម្ងឺ (ATSDR) ឆ្នាំ២០០១។ ការរៀបរាប់ពិស្ដារអំពីជាតិពុលរបស់អះបេះស្តុះ។ ចូលមើលនៅខែមេសាឆ្នាំ២០១៩ នៅ https://www.atsdr.cdc.gov/toxprofiles/tp61.pdf ។

របាយការណ៍ឆ្នាំ២០១៦ របស់ភ្នាក់ងារទទួលបន្ទុកខាងសុវត្ថិភាពជាមួយអះបេះស្តុះនិងការកំចាត់អះបេះស្តុះ។ ការប៉ាន់ស្មានអំពីបន្ទុករបស់ជម្ងឺ mesothelioma នៅប្រទេសអូស្ត្រាលីក្នុងអនាគត។ ចូលមើលនៅខែមេសាឆ្នាំ២០១៩ នៅ https://www.asbestossafety.gov.au/research-publications/future-projections-burden-mesothelioma- australia

វិទ្យាស្ថានសម្រាប់បរិស្ថាននិងសុខភាព (IEH)ឆ្នាំ២០០០។ គ្រោះថ្នាក់ និងសម្ភារៈជំនួសរបស់វា : ការវាយតម្លៃដោយប្រយ័ត្នប្រយែង។ ចូលមើលនៅខែមេសាឆ្នាំ២០១៩ នៅ http://www.iehconsulting.co.uk/IEH_Consulting/IEHCPubs/HumExpRiskAssess/w4.pdf

ភ្នាក់ងារអន្តរជាតិទទួលបន្ទុកខាងការស្រាវជ្រាវអំពីមហារីក(IARC) ឆ្នាំ២០១២។ ឯកសារសិក្សាឯកទេស ភាគ 100C : អះបេះស្តុះ (Chrysotile, Amosite, Crocidolite, Tremolite, Actinolite and Anthophyllite)។ ចូលមើលនៅខែមេសាឆ្នាំ២០១៩ នៅ https://monographs.iarc.fr/iarc-monographs-volume-100casbestos-chrysotile-amosite-crocidolite-tremolite-actinolite-and-anthophyllite/

កម្មវិធីអន្តរជាតិស្តីអំពីសុវត្ថិភាពនៃជាតិគីមី (IPCS)ឆ្នាំ១៩៩៨។ កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ (UNEP), អង្គការពលកម្មអន្តរជាតិ (ILO) និងអង្គការសុខភាពពិភពលោក (WHO)។ របាយការណ៍អំពីអះបេះស្តុះគ្រីសូថាយ របស់ក្រុមលក្ខណៈវិនិច្ឆ័យ២០៣ នៃសុខភាពបរិស្ថាន។ ចូលមើលនៅខែមេសាឆ្នាំ២០១៩ នៅ http://www.inchem.org/documents/ehc/ehc/ehc203.htm

Kohyama N និង Suzuki Y ឆ្នាំ 1991។ ការវិភាគនៃសរសៃអះបេះស្តុះក្នុងដាលិកាសួត Pleural plaques និងដាលិកា mesothelioma របស់កម្មករធ្វើការទប់កំដៅនៅអាមេរិកខាងជើង។ របាយការណ៍ប្រចាំឆ្នាំរបស់វិទ្យាស្ថានវិទ្យាសាស្ត្រនៅញូយ៉ក 643(1):27–52។ ចូលមើលនៅខែមេសាឆ្នាំ២០១៩ នៅ https://nyaspubs.onlinelibrary.wiley.com/doi/abs/10.1111/j.1749 -6632.1991.tb24442.x?sid=nlm%3Apubmed

ការរៀបរាប់លក្ខណៈបច្ចេកទេសថ្នាក់ជាតិអំពីអះបេះស្តុះ (NAP) សម្រាប់ប្រទេសអូស្ត្រាលី ឆ្នាំ ២០១៧។ ចូលមើលនៅខែមេសាឆ្នាំ២០១៩ នៅ t https://www.asbestossafety.gov.au/research- publications/national-asbestos-profile-australia

កម្មវិធីថ្នាក់ជាតិសម្រាប់ផ្តល់ដំណឹងនិងវាយតម្លៃជាតិគីមីសម្រាប់ឧស្សាហកម្ម (NICNAS) ឆ្នាំ 1999។ ជាតិគីមីទីដែលកំពុងមានប្រកបដោយអាទិភាពលេខ៩ : អះបេះស្តុះគ្រីសូថាយ។ ចូលមើលនៅខែមេសាឆ្នាំ២០១៩ នៅ https://www.nicnas.gov.au/chemical-information/pec-assessments?result_34791_result_page=C

វិទ្យាស្ថានជាតិនៃវិទ្យាសាស្ត្រឧស្សាហកម្ម និងបច្ចេកវិទ្យាជឿនលឿន (AIST) ឆ្នាំ 2007។ ការបង្កើតទ្រនាប់បំពង់ដោយប្រើសម្ភារៈជំនួសអះបេះស្តុះ។ ចូលមើលនៅខែមេសាឆ្នាំ២០១៩ នៅ https://www.aist.go.jp/aist_e/list/latest_research/2007/20070206/20070206.html

កម្មវិធីជាតិនៃការសិក្សាជាតិពុល (NTP) ឆ្នាំ 2016។ របាយការណ៍បោះពុម្ពទី១៤ អំពីវត្ថុដែលអាចបង្កឲ្យមានមហារីកទាក់ទងនិងអះបេះស្តុះ ។ ចូលមើលនៅខែមេសាឆ្នាំ២០១៩ នៅ at https://ntp.niehs.nih.gov/ntp/roc/content/profiles/asbestos.pdf

គណៈកម្មធិការវិទ្យាសាស្ត្រស្តីអំពីជាតិពុល ជាតិពុលក្នុងបរិស្ថាន និងបរិស្ថាន (CSTEE) ឆ្នាំ 1988។ អះបេះស្តុះគ្រីសូថាយ និងបេក្ខភាពជំនួស។ ចូលមើលនៅខែមេសាឆ្នាំ២០១៩ នៅ http://ec.europa.eu/health/scientific_committees/environmental_risks/opinions/sctee/index_en.htm

Suzuki Y និង Yuen SR ឆ្នាំ 2006។ សរសៃអះបេះស្តុះរួមចំណែកបង្កឲ្យមនុស្សមានជម្ងឺកាចឈ្មោះ mesothelioma។


ASBESTOS SAFETY

របាយការណ៍ប្រចាំឆ្នាំរបស់វិទ្យាស្ថានវិទ្យាសាស្ត្រនៅញូយ៉ក 982(1):160–176។ ចូលមើលនៅខែមេសាឆ្នាំ២០១៩ នៅ
https://nyaspubs.onlinelibrary.wiley.com/doi/abs/10.1111/j.1749 -6632.2002.tb04931.x?sid=nlm%3Apubmed

ភ្នាក់ងារការពារបរិស្ថានរបស់សហរដ្ឋអាមេរិក (EPA) ឆ្នាំ1982។ ការវិភាគលើដំណើរការរបស់វត្ថុជំនួសអះបេះស្តុះ: របាយការណ៍ដែលបានពិនិត្យកែជាចុងក្រោយ (740R82003)។ ចូលមើលនៅខែមេសាឆ្នាំ២០១៩ នៅ
https://www.epa.gov/nscep

ភ្នាក់ងារការពារបរិស្ថានរបស់សហរដ្ឋអាមេរិក(EPA) ឆ្នាំ 1988។ ប្រព័ន្ធព័ត៌មានស្តីអំពីហានិភ័យ(IRIS) សេចក្តីសង្ខេបនៃការវាយតម្លៃគីមី : អះបេះស្តុះ។ ចូលមើលនៅខែមេសាឆ្នាំ២០១៩ នៅ
https://cfpub.epa.gov/ncea/iris/iris_documents/documents/subst/0371_summary.pdf

ភ្នាក់ងារការពារបរិស្ថានរបស់សហរដ្ឋអាមេរិក(EPA) ឆ្នាំ 1988។ ការរៀបរាប់ជាក់លាក់នៃការវាយតម្លៃហានិភ័យសម្រាប់អះបេះស្តុះ។ ចូលមើលនៅខែមេសាឆ្នាំ២០១៩ នៅ
https://www.epa.gov/sites/production/files/2018-06/documents/asbestos_problem_formulation_05-31-18.pdf

អង្គការសុខភាពពិភពលោក (WHO) ឆ្នាំ 2014។ អះបេះស្តុះគ្រីសូថាយ។ ចូលមើលនៅខែមេសាឆ្នាំ២០១៩ នៅ
https://apps.who.int/iris/bitstream/handle/10665/143649/9789241564816_eng.pdf;jsessionid=F66052EB1D7FF84946 BF5DBC13C EEB18?sequence=1